ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
គណៈកម្មការជ្រើសរើសពលទាហាន
បំពេញក្របខណ្ឌឲ្យយោធភូមិភាគទី១
កងទ័ពជើងគោក
លេខ: ២០៧/ ស.ជ.ណ /២០១៧

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧

## សេចក្តីជូនដំណឹង

### ស្តីពី៖ ការពិនិត្យសុខភាពបេក្ខជនដែលបានដាក់ពាក្យបម្រើការក្នុងកងយោធពលខេមរភូមិន្ទ ដើម្បីបំពេញក្របខណ្ឌនៅយោធភូមិភាគទី១ កងទ័ពជើងគោក

គណៈកម្មការជ្រើសរើសពលទាហានបំពេញក្របខណ្ឌឲ្យយោធភូមិភាគទី១ កងទ័ពជើងគោក មានកិត្តិយស សូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងអស់ ដែលបានដាក់ពាក្យបម្រើការងារជាយោធិននៃកងយោធពលខេមរភូមិន្ទឲ្យបានជ្រាបថា ៖ គណៈកម្មការជ្រើសរើសពលទាហាន នឹងទទួលពិនិត្យសុខភាពជូនបេក្ខជនទាំងអស់ **ចាប់ពីថ្ងៃទី២៥ ខែតុលា រហូតដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧** នៅបណ្តារាជធានី-ខេត្តទូទាំងប្រទេស។

អាស្រ័យហេតុនេះ សូមបេក្ខជនទាំងអស់ប្រញាប់មកទទួលការពិនិត្យសុខភាពឲ្យបានទាន់ពេលវេលា ដោយភ្ជាប់មកជាមួយឯកសារសាលាកបត្រដាក់ពាក្យ និងអញ្ជើញទៅកាន់មន្ទីរពេទ្យក្នុងរាជធានី-ខេត្ត ដែលខ្លួនបានដាក់ពាក្យដូចខាងក្រោម ៖

| ល.រ | រាជធានី-ខេត្ត | ទីតាំងពិនិត្យសុខភាព |
|---|---|---|
| ១ | ស្ទឹងត្រែង | មន្ទីរពេទ្យយោធភូមិភាគទី១ |
| ២ | រតនៈគិរី | មន្ទីរពេទ្យបង្អែករតនៈគិរី |
| ៣ | មណ្ឌលគិរី | មន្ទីរពេទ្យបង្អែកមណ្ឌលគិរី |
| ៤ | ស្វាយរៀង | មន្ទីរពេទ្យបង្អែកស្វាយរៀង |
| ៥ | ព្រៃវែង | មន្ទីរពេទ្យបង្អែកព្រៃវែង |
| ៦ | ក្រចេះ | មន្ទីរពេទ្យបង្អែកក្រចេះ |
| ៧ | ត្បូងឃ្មុំ | មន្ទីរពេទ្យបង្អែកត្បូងឃ្មុំ |
| ៨ | កំពង់ចាម | មន្ទីរពេទ្យយោធភូមិភាគទី២ |
| ៩ | កំពង់ស្ពឺ | មន្ទីរពេទ្យបង្អែកកំពង់ស្ពឺ |
| ១០ | កំពត | មន្ទីរពេទ្យបង្អែកកំពត |
| ១១ | កែប | មន្ទីរពេទ្យបង្អែកកែប |
| ១២ | កោះកុង | មន្ទីរពេទ្យបង្អែកកោះកុង |
| ១៣ | ព្រះសីហនុ | មន្ទីរពេទ្យបង្អែកព្រះសីហនុ |
| ១៤ | តាកែវ | មន្ទីរពេទ្យបង្អែកតាកែវ |
| ១៥ | សៀមរាប | មន្ទីរពេទ្យយោធភូមិភាគទី៤ |
| ១៦ | កំពង់ធំ | មន្ទីរពេទ្យបង្អែកកំពង់ធំ |
| ១៧ | ព្រះវិហារ | មន្ទីរពេទ្យបង្អែកព្រះវិហារ |
| ១៨ | ឧត្តរមានជ័យ | មន្ទីរពេទ្យបង្អែកឧត្តរមានជ័យ |
| ១៩ | បាត់ដំបង | មន្ទីរពេទ្យយោធភូមិភាគទី៥ |
| ២០ | ពោធិ៍សាត់ | មន្ទីរពេទ្យបង្អែកពោធិសាត់ |
| ២១ | ប៉ៃលិន | មន្ទីរពេទ្យបង្អែកប៉ៃលិន |
| ២២ | បន្ទាយមានជ័យ | មន្ទីរពេទ្យបង្អែកមង្គលបូរី |
| | | មន្ទីរពេទ្យបង្អែកប៉ោយប៉ែត |
| | | មន្ទីរពេទ្យបង្អែកថ្មពួក |
| ២៣ | កំពង់ឆ្នាំង | មន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង |
| ២៤ | កណ្តាល | មន្ទីរពេទ្យបង្អែកកណ្តាល |
| ២៥ | ភ្នំពេញ | មន្ទីរពេទ្យព្រះកេតុមាលា |

**បញ្ជាក់** ៖ មិនមានការបង់ប្រាក់សម្រាប់ការពិនិត្យសុខភាពនេះឡើយ។ ព័ត៌មានបន្ថែម ឬ ករណីមានបុគ្គលឆ្លៀតឱកាស សូមសហការផ្តល់ព័ត៌មានមកក្រុមការងារ តាមទូរស័ព្ទលេខ 085333944 / 085222744 / 0972666241 /0972666240 / 086847300 / 086685570 ។

**គណៈកម្មការជ្រើសរើសពលទាហាន**